ព្រះរាជាណាចក្រកម្ពុជា

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំចក្រភពអង់គ្លេស

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹង
## ស្តីពី
## កម្មវិធីរាត្រីភាពយន្តកម្ពុជានៃមហោស្រពភាពយន្តអាស៊ានឆ្នាំ២០២៤

ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំចក្រភពអង់គ្លេស មានកិត្តិយសសូមជម្រាបជូនថា គណៈកម្មាធិការអាស៊ាន នៅទីក្រុងឡុងដ៍ នឹងរៀបចំ**កម្មវិធីមហោស្រពភាពយន្តអាស៊ានឆ្នាំ២០២៤**។ ព្រឹត្តិការណ៍នេះ នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃចន្ទ **ទី២២** ដល់ថ្ងៃសៅរ៍ **ទី២៧ ខែមេសា ឆ្នាំ២០២៤** នៅសាកលវិទ្យាល័យ SOAS ដោយនឹងបង្ហាញអំពីទេពកោសល្យភាពយន្តដ៏រស់រវើកនៃតំបន់អាស៊ាន។

ក្នុងឱកាសកម្មវិធីរាត្រីភាពយន្តកម្ពុជានៃមហោស្រពភាពយន្តអាស៊ានឆ្នាំ២០២៤ ស្ថានទូតមានមោទកភាពក្នុងការចាក់បញ្ចាំងភាពយន្តរឿង **"ពេលម៉ាក់ចាស់ទៅ"** ដែលនិពន្ធ និងដឹកនាំដោយ**អ្នកស្រី ពាន់ ភួងបុប្ផា** នៅ**ថ្ងៃពុធ ទី២៤ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ៦ល្ងាច** នៅ Brunei Gallery ក្នុងសាកលវិទ្យាល័យ SOAS នៅទីក្រុងឡុងដ៍ ដែលមានអាសយដ្ឋាន៖ Thornhaugh Street, Russell Square, London WC1H 0XG។

សេចក្តីដូចបានជម្រាបជូនខាងលើ ស្ថានឯកអគ្គរាជទូត សូមអញ្ជើញប្រជាពលរដ្ឋ និងសិស្ស-និស្សិតខ្មែរដែលកំពុងរស់នៅ និងសិក្សានៅចក្រភពអង់គ្លេសចូលរួមកម្មវិធីខាងលើនេះ។ ព័ត៌មានលម្អិតនៃកម្មវិធីមហោស្រពភាពយន្តអាស៊ានឆ្នាំ២០២៤ នឹងត្រូវជម្រាបជូននៅពេលក្រោយ។ អាស្រ័យដោយចំនួនសំបុត្រចូលរួមទស្សនាភាពយន្តកម្ពុជាមានកំណត់ សូមប្រជាពលរដ្ឋ និងសិស្ស-និស្សិតខ្មែរមេត្តាចុះឈ្មោះតាមរយៈ Link៖ https://forms.office.com/r/0tZBfwfZNk ឱ្យបានមុន**ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤**។

សូមអរគុណ!

ថ្ងៃអង្គារ ០៩ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ទីក្រុងឡុងដ៍, ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤

សូម Scan QR Code
ដើម្បីចុះឈ្មោះ

64 Brondesbury Park, Willesden Green, London NW6 7AT, Tel: +44 20 8451 7850, Fax: +44 20 8451 7594
Email: cambodianembassy@btconnect.com Website: www.cambodianembassy.org.uk